**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅកំពង់ចម្លង**
**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨**
***ទទួលជីវិតថ្មីតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ***

| |
|---|
| អត្ថបទទី១៖ ប្រាញ ១,១៣-១៥ និង ២,២៣-២៤ |
| អត្ថបទទី២៖ ២ករ ៨,៧.៩.១៣-១៥ |
| ដំណឹងល្អ៖ មក ៥,២១-៤៣ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងស្តាប់រឿងមួយដែលណែនាំឲ្យយើងចាប់អារម្មណ៍ អំពីរបៀបដែលព្រះយេស៊ូបានព្យាបាល របៀបដែលព្រះយេស៊ូធ្វើជាមួយមនុស្ស។ ពេលព្រះយេស៊ូ ដើរពីភូមិមួយទៅភូមិមួយ មានមហាជនដែលមកស្តាប់ព្រះយេស៊ូ គេចង់ឃើញ គេចង់ស្គាល់ គេចង់ឮ ដោយសារគេនិយាយតៗគ្នាថាពេលព្រះយេស៊ូគង់នៅកន្លែងណាមួយ អ្នកជំងឺជាសះស្បើយ ជនពិការអាចដើរបាន មនុស្សខ្វាក់មើលឃើញ។ ដូច្នេះនៅពេលព្រះយេស៊ូដើរ គេមកយ៉ាងច្រើនដើម្បីមើល ដើម្បីស្តាប់ និងជាពិសេសគេពោរពេញដោយសេចក្តីសង្ឃឹមដោយគិតថាធ្វើយ៉ាងម៉េចដើម្បីឲ្យខ្ញុំអាចជាសះស្បើយ?

នៅថ្ងៃនេះ យើងមានរឿងមួយជាមួយស្ត្រីដែលធ្លាក់ឈាម អស់រយៈពេល១២ឆ្នាំមកហើយ គាត់បានលក់ទ្រព្យសម្បត្តិ និងអ្វីៗទាំងអស់ដែលគាត់មានដើម្បីជួបជាមួយគ្រូពេទ្យ ប៉ុន្តែអត់ជាសះស្បើយសោះ។ គាត់មិនបានជួបជាមួយព្រះយេស៊ូផ្ទាល់ នៅមុខព្រះយេស៊ូផ្ទាល់ទេ ពេលនោះមហាជនច្រើនមែនទែន គេមកប៉ះព្រះយេស៊ូ គេមកមើលព្រះយេស៊ូ។ ស្ត្រីនោះប្លែក ដោយសារគាត់បានប៉ះជាយអាវរបស់ព្រះយេស៊ូ មិនមែននៅពីខាងមុខ ប៉ុន្តែខាងក្រោយ។ ថ្ងៃនោះមានមនុស្សច្រើនដែលកំពុងប៉ះព្រះយេស៊ូ មានខ្លះគេចាប់ដៃ មានខ្លះគេចង់ឱប មានខ្លះគេប៉ះជើងព្រះយេស៊ូ។ ប៉ុន្តែស្ត្រីនោះ ដែលបានប៉ះជាយអាវរបស់ព្រះយេស៊ូពីខាងក្រោយ ណែនាំឲ្យព្រះយេស៊ូបានការចាប់អារម្មណ៍ ដោយសារពេលនោះដូចជាមានអ្វីដែលចេញ ព្រះយេស៊ូមានព្រះបន្ទូលថា "**អ្នកណាពាល់អាវរបស់ខ្ញុំ?**" តាមពិតព្រះយេស៊ូដឹងហើយ។ ក្រោយមកគេតបទៅព្រះអង្គថា "**ព្រះគ្រូឃើញស្រាប់ហើយ មានមហាជននៅជិតព្រះអង្គច្រើនណាស់ និងទាំងអស់គ្នាគេកំពុងប៉ះព្រះយេស៊ូ**"។ ព្រះយេស៊ូទតមើលជុំវិញដើម្បីឲ្យដឹងថាអ្នកណាបានពាល់ព្រះអង្គ ស្ត្រីនោះភ័យព្រោះជាគាត់ដែលពាល់ព្រះអង្គ។ ប៉ុន្តែនៅពេលនោះព្រះយេស៊ូបានមើលឃើញជំនឿ មិនមែនជំងឺតែប៉ុណ្ណឹង តែជំនឿរបស់គាត់ ជឿថាតាមពិតស្ត្រីនោះគាត់ពោរពេញដោយជំនឿ និងគាត់ចង់មានជីវិតថ្មី ហេតុនេះហើយព្រះយេស៊ូមានព្រះបន្ទូលមួយដ៏សំខាន់ថា "**កូនស្រីអើយ! ជំនឿរបស់នាងបានស**

**ស្ត្រោះនាងហើយ! សូមអញ្ជើញទៅឲ្យបានសុខសាន្ត ហើយសូមឲ្យនាងបានជាសះស្បើយពីជំងឺចុះ!**"។ នេះជាឫទ្ធានុភាពរបស់ព្រះយេស៊ូ! ព្រះយេស៊ូណែនាំឲ្យយើងទទួលជីវិតថ្មី ដើម្បីឲ្យយើងមានជំនឿ។ នៅពេលយើងជឿលើព្រះយេស៊ូ យើងបានដឹងថា ជីវិតរបស់យើងមិនមែនដូចពីមុនទេ។ នៅពេលអធិដ្ឋានចូល យើងបានអធិដ្ឋានសម្រាប់ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីណែនាំឲ្យខ្ញុំធ្វើជាសញ្ញាសម្គាល់នៃពិភពលោកថ្មី និងប្អូន៣៥នាក់ដែលថ្ងៃនេះទទួលអគ្គសញ្ញាលាបថ្វាស ជាពេលវេលារិះគិត ខ្ញុំធ្វើយ៉ាងម៉េចដើម្បីទៅជាសញ្ញាសម្គាល់នៃពិភពលោកថ្មី? ដូចព្រះយេស៊ូពីដើម នៅពេលព្រះយេស៊ូដើរពីភូមិមួយទៅភូមិមួយ ណែនាំឲ្យអ្នកក្រីក្រ ណែនាំឲ្យអ្នកជំងឺពោរពេញដោយសេចក្តីសង្ឃឹម និងសេចក្តីសង្ឃឹមនេះ ណែនាំឲ្យគេមានជីវិតថ្មី។ យើងធ្លាប់បានស្តាប់រឿង ព្រះយេស៊ូដែលណែនាំឲ្យអ្នកជំងឺបានជាច្រើន និងជាពិសេសម្តាយរបស់លោកសិលា។ នៅពេលម្តាយរបស់លោកសិលាមានគ្រុន ព្រះយេស៊ូចូល ព្រះយេស៊ូពាល់គាត់ ហើយគាត់ជាសះស្បើយ និងគាត់មកធ្វើការវិញ ដោយសារគាត់មានកម្លាំងសារជាថ្មី។ តាមពិតព្រះយេស៊ូយាងមក ដើម្បីណែនាំឲ្យយើងមានកម្លាំងថ្មី ឲ្យយើងទៅជាមនុស្សថ្មី។ ព្រះវិញ្ញាណដ៏វិសុទ្ធជាកម្លាំងពិសេស ទោះបីយើងក្មេងក៏ដោយ យើងត្រូវការយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធជាកម្លាំងមួយសម្រាប់យើងខ្ញុំ ខ្ញុំជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ព្រះយេស៊ូបានជ្រើសរើសខ្ញុំឲ្យធ្វើជាមិត្តរបស់ព្រះអង្គ។ ដូច្នេះខ្ញុំធ្វើយ៉ាងម៉េចដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ហៀចេញពីខ្លួនខ្ញុំដើម្បីទៅដល់បងប្អូនឯទៀតៗអាចទទួលបាន។ នៅពេលស្ត្រីពាល់អាវរបស់ព្រះយេស៊ូ នៅពេលនោះដូចជាសេចក្តីស្រឡាញ់ដែលនៅពេញខ្លួនរបស់ព្រះយេស៊ូ បានចេញពីខ្លួនរបស់ព្រះយេស៊ូ ដើម្បីទៅដល់ស្ត្រីនោះ។ មានគ្រូពេទ្យប៉ុន្មានដែលមើលគាត់ គាត់ប្រើលុយរបស់គាត់អស់ហើយ តែគាត់មិនជាសះស្បើយ និងគាត់ពាល់ព្រះយេស៊ូតិចតួច គាត់មានជីវិតថ្មីដោយបានជាសះស្បើយផងដែរ នេះដោយសារគាត់ពោរពេញដោយសេចក្តីសង្ឃឹម។

ព្រះវិញ្ញាណដ៏វិសុទ្ធជាកម្លាំង ដើម្បីយល់ថាជីវិតយើងទៅដល់ជីវិតថ្មី ដោយសារយើងទទួលដង្ហើមរបស់ព្រះជាម្ចាស់។ ដង្ហើមរបស់ព្រះជាម្ចាស់ ជាខ្យល់របស់ព្រះជាម្ចាស់ដែលចូលទៅក្នុងសួត នៅក្នុងខ្លួនរបស់យើងដើម្បីឲ្យយើងទៅជាមនុស្សថ្មី។ មនុស្សថ្មីរបៀនណា? បន្តិចទៀតខ្ញុំនឹងអធិដ្ឋាន៖ **ព្រះវិញ្ញាណដ៏វិសុទ្ធ ផ្តល់ឲ្យមានប្រាជ្ញាឈ្លាសវៃ ព្រះវិញ្ញាណ នាំឲ្យចេះពិចារណាដឹងខុសដឹងត្រូវ ព្រះវិញ្ញាណ ផ្តល់ឲ្យដឹងសេចក្តីពិត ព្រះវិញ្ញាណ ផ្តល់ឲ្យមានយោបល់ល្អ។** នេះទាំងអស់ជាព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងទៅជាមនុស្សពេញ

លក្ខណៈ។ ទោះបីយើងជាក្មេងក៏ដោយ យើងដឹងថាចាប់ពីពេលនេះតទៅខ្ញុំដឹងថានេះល្អ នេះមិនល្អ នេះត្រឹមត្រូវ នេះមិនត្រឹមត្រូវ។

ដូច្នេះយើងត្រូវការមើលរបៀបព្រះយេស៊ូ ដូចខ្ញុំបាននិយាយនៅចំប៉ា ពីអាទិត្យមុនថា៖ **យើងធ្វើដូចម្ដេចដើម្បីយើងជាគ្រីស្តបរិស័ទល្អ?** ឲ្យយើងណែនាំឲ្យព្រះជាម្ចាស់ពេញចិត្តនឹងយើង។ **យើងធ្វើយ៉ាងម៉េចឲ្យព្រះជាម្ចាស់ពេញចិត្តនឹងយើង?** នេះជាគោលដៅនៃជីវិតរបស់យើង។ យើងធ្វើកូនល្អ យើងធ្វើគ្រីស្តបរិស័ទល្អ យើងធ្វើសិស្សសាលាល្អ យើងធ្វើមិត្តល្អ យើងធ្វើជាពលរដ្ឋល្អ ប៉ុន្តែសំខាន់អ្វីៗទាំងអស់ដែលយើងធ្វើ យើងត្រូវការនឹកឃើញថាតើព្រះជាម្ចាស់ពេញចិត្តឬអត់? តើព្រះជាម្ចាស់សប្បាយចិត្តឬអត់? ដើម្បីដឹងថាព្រះជាម្ចាស់សប្បាយចិត្តឬអត់ យើងត្រូវការមើលអ្វីដែលយើងធ្វើជាអំពើល្អ ឬអំពើអាក្រក់? ណែនាំឲ្យអ្នកដទៃមានសេចក្ដីសុខ ឬណែនាំឲ្យអ្នកដទៃពិបាកចិត្ត? នៅសាលាបើសិនខ្ញុំវាយពួកម៉ាកពួកម៉ាកខ្ញុំគេអត់មានសេចក្ដីសុខ។ នៅផ្សារបើសិនខ្ញុំនិយាយដើមគេ នៅផ្សារអត់មានសេចក្ដីសុខ។ នៅក្នុងភូមិរបស់យើងបើសិនយើងមើលងាយគ្នាទៅវិញទៅមក អត់មានសេចក្ដីសុខ។ បើសិននៅក្នុងព្រះសហគមន៍ យើងឈ្លោះគ្នារឿងនេះរឿងនោះ អត់មានសេចក្ដីសុខ។ នៅពេលនោះ យើងមិនណែនាំឲ្យព្រះជាម្ចាស់មានអំណរសប្បាយ។ ផ្ទុយទៅវិញព្រះជាម្ចាស់ចង់ឲ្យយើងពោរពេញអំណរសប្បាយ ដូច្នេះធ្វើយ៉ាងម៉េចដើម្បីធ្វើជាមនុស្សដែលយកចិត្តទុកដាក់ស្រឡាញ់ យកចិត្តទុកដាក់លើកទឹកចិត្ត យកចិត្តទុកដាក់មើលបងប្អូនឯទៀតៗដែលកំពុងមានទុក្ខលំបាក។ ប៉ុន្តែយើងដឹងហើយ ប៉ុន្មានដងប៉ុន្មានសារ យើងធ្លាក់ចុះធ្វើអំពើអត់ល្អ ឬធ្វើអំពើបាប ប៉ុន្តែយើងអត់អស់សង្ឃឹមទេ ដូចស្ដ្រីនោះ១២ឆ្នាំដែលគាត់ធ្លាក់ឈាម ១២ឆ្នាំដែលគាត់ឈឺ ១២ឆ្នាំដែលគាត់លក់អ្វីៗទាំងអស់ ដើម្បីព្យាបាលប៉ុន្តែចុងក្រោយបំផុតនៅពេលគាត់អស់ទ្រព្យសម្បត្តិ នៅពេលគាត់អស់សង្ឃឹមលើគ្រូពេទ្យ នៅពេលគាត់អស់សង្ឃឹមលើថ្នាំដើម្បីព្យាបាលគាត់។ គាត់នៅសល់សេចក្ដីសង្ឃឹមមួយ គឺព្រះយេស៊ូផ្ទាល់។ សេចក្ដីសង្ឃឹមនេះ ណែនាំឲ្យគាត់ទៅដល់ព្រះយេស៊ូ និងនៅក្នុងចិត្តគាត់គាត់គិតថាប្រសិនបើខ្ញុំពាល់ជាយអាវព្រះយេស៊ូប្រហែលខ្ញុំជាសះស្បើយ។ នេះជាសេចក្ដីសង្ឃឹមដែលចេញពីជំនឿ ដែលគាត់មាននៅលើព្រះយេស៊ូ ដោយសារគាត់ដឹងថាព្រះយេស៊ូជាព្រះជាម្ចាស់ផ្ទាល់ដែលកំពង់យាងមក។ ព្រះយេស៊ូ បានយល់ចិត្តគាត់ យល់ថាគាត់ចង់ជា គាត់ចង់ធ្វើជាមនុស្សថ្មី ដូច្នេះព្រះយេស៊ូណែនាំឲ្យគាត់ជាសះស្បើយ។ សម្រាប់យើងដូចគ្នា នៅពេលយើងដួល ពេលយើងធ្លាក់ ពេលយើងពិបាកកុំឲ្យយើងអស់សេចក្ដីសង្ឃឹម ឲ្យយើងគិតថាខ្ញុំមានកម្លាំងដោយសារព្រះជាម្ចាស់ ដើម្បីទៅជាមនុស្សថ្មីសារជាថ្មី

។ ទោះបីខ្ញុំពាល់ព្រះជាម្ចាស់ពីខាងក្រោយ ព្រះជាម្ចាស់ស្វាគមន៍ខ្ញុំទៀតដោយលើកលែងទោសឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំធ្វើដំណើរតទៅទៀត ដើម្បីឲ្យខ្ញុំធ្វើជាគ្រីស្តបរិស័ទដែលមានសេចក្តីសង្ឃឹមនៅក្នុងខ្លួនដោយសារព្រះជាម្ចាស់គង់នៅ និងព្រះជាម្ចាស់ធ្វើដំណើរជាមួយខ្ញុំ នេះជាសេចក្តីសង្ឃឹមរបស់យើង។

គម្ពីរដំណឹងល្អថ្ងៃនេះ ជាគម្ពីរមួយដែលត្រូវការចូលនៅក្នុងជីវិតយើង ដើម្បីណែនាំឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច។ ទោះបីយើងអស់សង្ឃឹមលើមនុស្ស អស់សង្ឃឹមលើព្រះសហាគមន៍ អស់សង្ឃឹមលើបូជាចារ្យ អស់សង្ឃឹមលើលោកអភិបាល អស់សង្ឃឹមលើអ្នកដឹកនាំប្រទេសយើង អស់សង្ឃឹមលើអាជ្ញាធរដែនដី អស់សង្ឃឹមលើអ្វីៗទាំងអស់នៅក្នុងសង្គម ក៏ប៉ុន្តែយើងនៅសល់សង្ឃឹមមួយគឺ "ព្រះជាម្ចាស់" ដោយសារព្រះជាម្ចាស់ជាទីពឹងរបស់យើង ដែលមិនលះបង់ចោលយើង។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះ ដើម្បីធ្វើដំណើរជាមួយមនុស្សលោកជានិច្ច គឺជាមួយយើងរៀងៗខ្លួន។ យើងដឹងថានៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះជាម្ចាស់បានទទួលយើងជាបុត្រាជាបុត្រីរបស់ព្រះអង្គ។ នេះជាសេចក្តីសង្ឃឹមអស់មួយជីវិតរហូតដល់យើងស្លាប់ ទោះបីយើងមិនអាចសង្ឃឹមស្ថាប័ន យើងមិនអាចសង្ឃឹមលើអ្នកដឹកនាំយើង ប៉ុន្តែយើងដឹងថាព្រះជាម្ចាស់គង់នៅ។ នេះណែនាំឲ្យយើងទៅមុន ដើម្បីកសាងសង្គមថ្មីប្រកបដោយសេចក្តីសង្ឃឹម សម្រាប់អ្នកដទៃដែរ។ ដោយសារស្ត្រីនោះពេលគាត់ជាសះស្បើយ យើងជឿថាគាត់ទៅប្រាប់គេដើម្បីផ្តល់សាក្ខីភាពថាគាត់បានជាសះស្បើយ ដូចស្ត្រីសាសន៍សាម៉ារី ដែលគេមើលងាយ នៅពេលគាត់ជួបជាមួយព្រះយេស៊ូហើយ នៅពេលព្រះយេស៊ូបានណែនាំឲ្យគាត់យល់ថាព្រះយេស៊ូជាទឹកដែលផ្តល់ជីវិតយ៉ាងពិតប្រាកដ គាត់សប្បាយចិត្តនិងប្រកាសឲ្យគេដឹង។ មនុស្សឃ្លង់ពេលគាត់ជាសះស្បើយ ទោះបីព្រះយេស៊ូហាមមិនឲ្យប្រាប់គេ គាត់រត់ទៅដើម្បីប្រាប់ពីបទពិសោធន៍ដែលគាត់ជួបជាមួយព្រះយេស៊ូ និងណែនាំឲ្យគាត់មានជីវិតថ្មី។ ដូចគ្នាជាមួយមនុស្សខ្វាក់ ដូចគ្នាជាមួយមនុស្សឃ្លង់ គាត់សប្បាយចិត្តណាស់ សម្រាប់យើងក៏ដូចគ្នាដែរ។ នៅពេលយើងបានជួបជាមួយព្រះយេស៊ូ ណែនាំឲ្យយើងទទួលជីវិតថ្មី យើងទុកសម្រាប់ខ្លួនយើងអត់បាន យើងចែករំលែកជាមួយបងប្អូនឯទៀតៗ។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាកម្លាំងថ្មី ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាសេចក្តីសង្ឃឹម និងជាពិសេសព្រះវិញ្ញាណដ៏វិសុទ្ធដែលជាសេចក្តីស្រឡាញ់ដែលចេញពីព្រះជាម្ចាស់ ដើម្បីចូលនៅក្នុង

ជីវិតរបស់យើងផ្ទាល់។ យើងអរព្រះគុណព្រះអង្គ យើងត្រៀមខ្លួនទាំងអស់គ្នា ដើម្បីទទួលជីវិតថ្មីតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន៕